ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..........................

# សេចក្តីប្រកាសព័ត៌មាន
## អ្នកនាំពាក្យក្រសួងការពារជាតិ

នៅម៉ោង១៩៖១២នាទីយប់ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ (ម៉ោងនៅប្រទេសម៉ាលី) ត្រូវនឹងព្រឹកថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ (ម៉ោងនៅកម្ពុជា) មានករណីបំផ្ទុះគ្រាប់បែកអត្តឃាតមួយ បង្កឡើងដោយក្រុមភេរវករបើករថយន្ត១គ្រឿង ចូលទៅបំផ្ទុះក្នុងទីតាំងស្នាក់នៅរបស់អង្គការសហប្រជាជាតិ នៅតំបន់ហ្គាវ ប្រទេសម៉ាលី។

ហេតុការណ៍នេះ បានបណ្តាលឱ្យភេរវករម្នាក់ដែលធ្វើសកម្មភាពបំផ្ទុះគ្រាប់បែកស្លាប់នៅនឹងកន្លែង និងបាត់បង់ជីវិតជនជាតិម៉ាលី២នាក់ ព្រមទាំងមានអ្នករបួស១៤នាក់ ដែលក្នុងនោះ ក៏មានពលរដ្ឋខ្មែរដែលធ្វើការជាមួយអង្គការសហប្រជាជាតិ ចំនួន៤នាក់ផងដែរ (ម្នាក់របួសធ្ងន់ និង៣នាក់ទៀតរបួសស្រាល)។

*** ចំណែកកម្លាំងរក្សាសន្តិភាពរបស់កម្ពុជា (ទាហានមួកខៀវ) ដែលបំពេញបេសកកម្មនៅតំបន់នេះ មិនមានគ្រោះថ្នាក់ដោយហេតុការណ៍ខាងលើទេ។**

រហូតមកដល់ពេលនេះ ជនរងគ្រោះជនជាតិខ្មែរដែលរបួសធ្ងន់នោះ ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យកម្រិត២ របស់ចិននៅក្នុងប្រទេសម៉ាលី ចំណែកឯអ្នករបួសស្រាលត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យក្បែរនោះ៕

ថ្ងៃពុធ ៧កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨